# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣ លើកទី ១៥

CDRI
Cambodia Development Resource Institute

## ចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ

# ២០៣០

## និងឆ្នាំបន្តបន្ទាប់ទៀត៖ ការកំណត់មាគ៌ាសម្រាប់វិបុលភាពប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន

"រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់ការប្តេជ្ញាចិត្តឥតងាករេ ក្នុងការសម្រេចឱ្យបាននូវការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ [...] កម្ពុជាចាំបាច់ត្រូវប្រកាន់យកស្មារតីនៃ 'ការកែទម្រង់ជាប្រចាំ និងបុរេសកម្មជានិច្ច' ដោយព្យាយាមកសាងឱ្យបាននូវភាពធន់ និងលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ច។"

*សុន្ទរកថារបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*
*ថ្លែងក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី១៥*

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី១៥ ដែលបានប្រារព្ធធ្វើនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ បានទទួលការអញ្ជើញចូលរួមពីសម្នាក់អ្នកមានឥទ្ធិពលក្នុងការធ្វើសេចក្តីសម្រេចចិត្តចំនួន ៥០០នាក់ ពីរាជរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងគ្រឹះស្ថានឧត្តមសិក្សាដើម្បីពិភាក្សាអំពីប្រធានបទសំខាន់ៗជុំវិញគោលនយោបាយអភិវឌ្ឍន៍នៅប្រទេសកម្ពុជា។ សន្និសីទចក្ខុវិស័យឆ្នាំ២០២៣ នេះផ្អែកលើគម្រោងស្រាវជ្រាវកំពុងបន្តមួយរបស់វិទ្យាស្ថាន CDRI លើប្រធានបទ "ចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៣០៖ ការវាយតម្លៃលើគោលដៅចំណូលមធ្យមកម្រិតខ្ពស់របស់ប្រទេសកម្ពុជាសម្រាប់កំណើនប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន"។ គម្រោងស្រាវជ្រាវនេះត្រូវបានធ្វើឡើងដើម្បីឆ្លើយសំណួរសំខាន់ៗ ថាតើកម្ពុជានឹងសម្រេចចក្ខុវិស័យរបស់ខ្លួន ឬមិនសម្រេច នៅពេលណា និងដោយរបៀបណា។ ការស្រាវជ្រាវ ក៏វិភាគអាទិភាពរយៈពេលខ្លី មធ្យម និងវែងរបស់កម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់ទៀត។ សន្និសីទចក្ខុវិស័យឆ្នាំ២០២៣ បានផ្តោតសំខាន់ទៅលើការពិភាក្សាអំពីបញ្ហាប្រឈមដែលកំពុងកើតមានឡើង និងកំណត់ទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្រដែលភាគីពាក់ព័ន្ធសំខាន់ៗត្រូវយល់ដឹង ដើម្បីសម្រេចចក្ខុវិស័យរបស់កម្ពុជាក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ សេចក្តីសង្ខេបចក្ខុវិស័យនេះបង្ហាញបរិការណ៍គោលដែលបានពិភាក្សាក្នុងសន្និសីទពាក់ព័ន្ធទៅនឹងហានិភ័យ និងកាលានុវត្តភាពនៅចំពោះមុខ មុនពេលយកចិត្តទុកដាក់ទៅលើ សកម្មភាពគោលនយោបាយបន្ទាន់នានាដែលចាំបាច់ដើម្បីជំរុញប្រទេសកម្ពុជាឱ្យឆាប់បានសម្រេចចក្ខុវិស័យដែលជាមហិច្ឆតារបស់ខ្លួន។

## កម្ពុជាមានចក្ខុវិស័យប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០

ដើម្បីផ្លាស់ប្តូរឋានៈកម្ពុជា ពីប្រទេសមានចំណូលមធ្យមកម្រិតទាប (LMIC) ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ (UMIC) ចំណូលសម្រាប់ពលរដ្ឋកម្ពុជាម្នាក់ៗ (GNI per capita of current US$) ត្រូវកើនឡើងពីកម្រិតបច្ចុប្បន្នចំនួន ១.៧០០ដុល្លារ (ជាតួលេខក្នុងឆ្នាំ២០២២) ទៅយ៉ាងហោចណាស់ចំនួន ៤.០៤៦ដុល្លារ ក្នុងឆ្នាំ២០៣០ (យោងតាមចំណាត់ថ្នាក់របស់ធនាគារពិភពលោកឆ្នាំ២០២២[១])។ មុនពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ អត្រាកំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់របស់ប្រទេសកម្ពុជា ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ បានធ្វើឱ្យចក្ខុវិស័យសម្រាប់ឋានៈជា ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ជាគោលដៅដែលអាចសម្រេចបាន។ ជាអកុសល សេដ្ឋកិច្ចកម្ពុជា ត្រូវរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ច ក្នុងតំបន់ និងពិភពលោកជាបន្តបន្ទាប់ ដែលបណ្តាលឱ្យមានកំណើនអតិផរណា និងអស្ថិរភាពភូមិសាស្ត្រនយោបាយ។

មុននឹងការមកដល់នៃជំងឺរាតត្បាត ការធ្វើពិពិធកម្មសេដ្ឋកិច្ចមានកម្រិតរបស់កម្ពុជា មិនបានធ្វើឱ្យប៉ះពាល់ខ្លាំងដល់សម្ទុះលឿននៃកំណើននោះទេ (សូមមើលតួលេខខាងក្រោម) ប៉ុន្តែ វាប៉ះពាល់ដល់ព្រំដែនបរិយាបន្ន ទៅលើ អ្នកដែលចូលរួមចំណែកក្នុងកំណើននោះ។ នៅចន្លោះឆ្នាំ២០១០ និង២០១៩ ប្រទេសកម្ពុជាបានឆ្លងកាត់បរិវត្តកម្មរចនាសម្ព័ន្ធ ដែលពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក ពីជនបទទៅទីក្រុង ពីព្រោះកម្លាំងពលកម្ម បានផ្លាស់ប្តូរពីរកសិកម្ម ទៅឧស្សាហកម្ម និងសេវាកម្មវិញ។ ទោះជាយ៉ាងនេះក្តី

១ ផ្អែកតាមធនាគារពិភពលោកនៅឆ្នាំ២០២២ សេដ្ឋកិច្ចដែលមានប្រាក់ចំណូលជាតិក្នុងមនុស្សម្នាក់ (GNI) ពី ១.០៣៦ដុល្លារ ទៅ ៤.០៤៥ដុល្លារ ត្រូវបានចាត់ថ្នាក់ជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងសេដ្ឋកិច្ចដែលមាន GNI ពី ៤.០៤៦ដុល្លារ ទៅ ១២.៥៣៥ដុល្លារ ចាត់ជាប្រជាជាតិមានចំណូលមធ្យមកម្រិតខ្ពស់។

កំណើន ផសស និងការរួមចំណែកខាងការផ្គត់ផ្គង់ ចន្លោះឆ្នាំ២០១០ ទៅ ២០២៣ (ពីមួយឆ្នាំទៅមួយឆ្នាំ ជាភាគរយ)




បរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចទាំងនេះ ប្រហែលជាឈានដល់ដែនកំណត់ហើយ។ ការពឹងផ្អែកទៅលើការបង្កើតផលិតផល និងសេវាកម្មដែលមានតម្លៃបន្ថែមខ្ពស់លើវិស័យតែមួយចំនួន បានជួយបង្កើនផលិតភាពបណ្ដោះអាសន្ន ដែលមិនមាននិរន្តរភាពរយៈពេលវែង។ ដូច្នេះនាពេលអនាគត កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ត្រូវកើតចេញពីការធ្វើពិពិធកម្មក្នុងរង្វង់វិស័យនានា ដែលតម្រូវឱ្យមានការផ្លាស់ប្ដូរទៅការផលិត និងសេវាកម្ម ដែលផ្ដល់តម្លៃបន្ថែមខ្ពស់លើគ្រប់វិស័យ។ ជាញឹកញាប់ ការធ្វើពិពិធកម្មប្រភេទនេះ ត្រូវបានហៅថា ជាការផ្លាស់ប្ដូរខ្សែចង្វាក់តម្លៃ។ នៅក្នុងវិស័យកម្មន្តសាល ការផ្លាស់ប្ដូរខ្សែចង្វាក់តម្លៃ តម្រូវឱ្យមានការចូលរួមកាន់តែច្រើននៅក្នុង ខ្សែចង្វាក់ផ្គត់ផ្គង់ពិភពលោក ដែលកម្ពុជាបានចាប់ផ្ដើមធ្វើរួចមកហើយ ប៉ុន្តែត្រូវចូលរួមឱ្យបានកាន់តែខ្លាំងថែមទៀត។ បរិវត្តកម្មរចនាសម្ព័ន្ធប្រភេទថ្មីនេះ នឹងតម្រូវឱ្យមានដំណោះស្រាយ ចំពោះឧបសគ្គទាក់ទងនឹងមូលធនមនុស្ស ថ្លៃដើមអាជីវកម្ម ព្រមទាំងគុណភាពស្ថាប័ន និងអភិបាលកិច្ច។

ថ្មីៗនេះ វិទ្យាស្ថាន CDRI បានធ្វើសិក្ខាសាលាពិគ្រោះយោបល់ និងការវិភាគជាបឋម ជាមួយភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ ទាក់ទងនឹងការស្រាវជ្រាវរបស់ខ្លួន ស្ដីពីចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៣០។ លទ្ធផលបានបង្ហាញឱ្យឃើញថា ការសម្រេចបាននូវគោលដៅឆ្នាំ២០៣០ គឺជាកិច្ចការប្រកបដោយមហិច្ឆតាមួយ ក្នុងពេលដែលមានបញ្ហាប្រឈមផ្នែកភូមិសាស្ត្រនយោបាយ និងការប្រែប្រួលយ៉ាងរហ័សនៃបរិយាកាសសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។ ការសម្រេចបានឋានៈជា ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ គឺទាមទារឱ្យមាន ការធ្វើកំណែទម្រង់ស៊ីជម្រៅ ជាច្រើនដើម្បីដោះស្រាយឧបសគ្គធំៗ ដែលរារាំងដល់កំណើននិងការអភិវឌ្ឍរយៈពេលវែង។

អ្នកចូលរួមក្នុងសន្និសីទចក្ខុវិស័យនៅឆ្នាំនេះ មានមតិឯកភាព ក្នុងការដាក់ឱ្យមានគោលដៅបន្ថែមចំនួនពីរទៀតដែលត្រូវបំពេញ ដើម្បីធ្វើឱ្យកម្ពុជាសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៣០។ គោលដៅទីមួយ ដើម្បីសម្រេចចក្ខុវិស័យឆ្នាំ២០៣០ យ៉ាងពិតប្រាកដ និងប្រកបដោយនិរន្តរភាព កម្ពុជាមិនត្រូវគិតត្រឹមតែធ្វើយ៉ាងណា ឱ្យមានកំណើនសេដ្ឋកិច្ចនោះទេ។ ផ្ទុយទៅវិញ កម្ពុជាត្រូវតែធានាថា កំណើននោះគឺប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន។ ការផ្ដល់អាទិភាពលើគោលនយោបាយ ដែលរួមបញ្ចូលទាំងស្ត្រី និងជនពិការ តាមរយៈការប្រយុទ្ធប្រឆាំងនឹងការរើសអើងក្នុងការជ្រើសរើសបុគ្គលិក និងការដំឡើងតួនាទីតាមរយៈការផ្ដល់ប្រាក់ឧបត្ថម្ភថែទាំកុមារ និងការធានាបាននូវ ប្រាក់ឈ្នួលខ្ពស់ និងសន្តិសុខនៅកន្លែងធ្វើការ នឹងធ្វើឱ្យកម្លាំងពលកម្មរបស់ប្រទេសកម្ពុជា មានភាពរឹងមាំនាពេលអនាគត។ គោលដៅទីពីរ កម្ពុជាមិនត្រូវផ្ដល់អាទិភាព ចំពោះតែការសម្រេចឱ្យបាននូវចក្ខុវិស័យឆ្នាំ២០៣០ ប៉ុណ្ណោះទេ ប៉ុន្តែត្រូវកសាងមូលដ្ឋានគ្រឹះរបស់ខ្លួន សម្រាប់វឌ្ឍនភាពនាពេលអនាគត ឆ្ពោះទៅសម្រេចបាននូវឋានៈជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ផងដែរ។ ការគិតគូរបែបនេះ នឹងនាំឱ្យប្រទេសកម្ពុជាជៀសផុតពីអន្ទាក់នៃប្រទេសមានចំណូលមធ្យម ដែលប្រទេសជាច្រើនជុំវិញពិភពលោក ធ្លាប់បានជួបប្រទះ។ គោលដៅទាំងពីរនេះ ក៏នឹងតម្រូវឱ្យមានការយកចិត្តទុកដាក់ជានិច្ច ក្នុងការពង្រឹងមូលដ្ឋានគ្រឹះនៃមូលធនមនុស្ស និងស្ថាប័នប្រកបដោយនិរន្តរភាព ដែលគាំទ្រដល់ការអភិវឌ្ឍរយៈពេលវែង។

## អាទិភាពកំណែទម្រង់គន្លឹះ

# ៧ ចំណុច៖

លទ្ធផលនៃសន្និសីទនេះ បានសម្រេចចេញជាអាទិភាពកំណែទម្រង់គន្លឹះចំនួន ៧ ដែលមានសារៈសំខាន់ សម្រាប់ការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល ព្រមទាំងចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់ទៀត។

### អាទិភាពទី១៖ ការដោះស្រាយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ ដោយអនុវត្តគោលនយោបាយអាទិភាពរយៈពេលខ្លី

- ការផ្តល់កម្មវិធីសិក្សាបំប៉នបន្ថែមនានា និងដោះស្រាយបញ្ហានូវការបាត់បង់ឱកាសសិក្សារបស់សិស្សដោយសារតែការបិទសាលារៀន អស់រយៈពេលយូរក្នុងអំឡុងពេលជំងឺរាតត្បាត។ អាទិភាពមួយទៀតគឺការដោះស្រាយបញ្ហាបោះបង់ការសិក្សា ដែលកំពុងតែកើនឡើងនាពេលថ្មីៗនេះ ដើម្បីគាំទ្រដល់កម្លាំងការងារនាពេលអនាគតរបស់កម្ពុជា ឱ្យបន្តទទួលបានការអប់រំ។
- ការបន្តអភិវឌ្ឍកម្មវិធីគាំពារសង្គម នឹងអាចកាត់បន្ថយផលប៉ះពាល់ពីភាពក្រីក្រ។
- កម្ពុជាចាំបាច់ត្រូវធានាឱ្យបាននូវ ការវិនិយោគផ្ទាល់ពីបរទេស (FDI) ក្នុងវិស័យកម្មន្តសាលឱ្យកាន់តែច្រើនថែមទៀត និងត្រូវកំណត់ទីតាំងរបស់ខ្លួនជាថ្មីនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ពិភពលោក។ កម្ពុជាអាចនឹងធ្វើយ៉ាងនេះបាន ដោយការបន្តបង្កើននូវភាពប្រកួតប្រជែងជាបន្ទាន់ តាមរយៈការធ្វើកំណែទម្រង់ និងបង្ហាញពីការប្តេជ្ញាចិត្តដែលអាចជឿទុកចិត្តបាន ចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងការធ្វើកំណែទម្រង់ជាបន្តទៀត ទៅលើបទប្បញ្ញត្តិអាជីវកម្ម ហេដ្ឋារចនាសម្ព័ន្ធ កម្លាំងពលកម្មជំនាញ និងការពង្រឹងស្តង់ដារបរិស្ថាន និងការងារ។

### អាទិភាពទី២៖ ការលើកកម្ពស់ស្ថាប័នប្រកបដោយគណនេយ្យភាព និងបរិយាបន្ន ដើម្បីផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់

- ការបង្កើតរដ្ឋាភិបាលប្រកបដោយ គណនេយ្យភាព និងបរិយាបន្ន ទាមទារឱ្យមានការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័ន ដើម្បីឱ្យស្ថាប័នអាចរៀបចំដំណើរការបានល្អក្នុងការបង្កើត ការអនុវត្ត និងការវាយតម្លៃគោលនយោបាយ និងផលប៉ះពាល់តាមទស្សនៈផ្សេងៗគ្នា។
- ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រកបដោយគុណភាព គឺជាកត្តាសំខាន់សម្រាប់ការតាក់តែងគោលនយោបាយប្រកបដោយប្រសិទ្ធភាព។ លក្ខណៈចាំបាច់នៃការគ្រប់គ្រងទិន្នន័យ រួមមាន ការកំណត់និយមន័យសមត្ថភាព និងការអនុវត្តការងាររបស់មន្ត្រីរដ្ឋាភិបាល ការប្រមូលទិន្នន័យសេដ្ឋកិច្ច-សង្គមសំខាន់ៗជាប្រព័ន្ធ និងការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាធរមាន ដែលមានលក្ខណៈហ្មត់ចត់ជាងមុន។
- ការប្រើប្រាស់ទិន្នន័យ និងឧបករណ៍វាយតម្លៃដើម្បីវាស់វែងផលប៉ះពាល់នៃការចែកចាយ តាមរយៈការប្រមូលទិន្នន័យ ដែលមានស្តង់ដារទាក់ទងនឹងតម្រូវការរបស់គ្រួសារមានចំណូលទាប និងក្រុមងាយរងហានិភ័យ នឹងជួយឱ្យប្រទេសកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ ប្រកបដោយបរិយាបន្នរបស់ខ្លួន។ ទិន្នន័យដទៃទៀត ដែលបានមកពីអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងយន្តការគណនេយ្យភាពសង្គម គួរតែត្រូវបានដាក់បញ្ចូលជាប្រចាំ និងជាប្រព័ន្ធដើម្បីជូនជាព័ត៌មានសម្រាប់ការតាក់តែងគោលនយោបាយ។
- ការលើកកម្ពស់ សេវាអេឡិចត្រូនិក និងការធ្វើឌីជីថលនីយកម្មនូវ កម្មវិធីទំនាក់ទំនងពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ ដូចជាកម្មវិធីគាំពារសង្គមជាដើម ក៏នឹងផ្តល់នូវមូលដ្ឋានគ្រឹះ ធ្វើឱ្យរដ្ឋាភិបាលកាន់តែមានភាពវៃឆ្លាត និងមានប្រសិទ្ធភាពជាងមុនផងដែរ។ លើសពីនេះ ឌីជីថលភាវូបនីយកម្មក៏អាចលើកកម្ពស់តម្លាភាព និងអាចឱ្យអ្នកតាក់តែងគោលនយោបាយប្រើប្រាស់វិធីបង្កើតទិន្នន័យ និងការវិភាគបានទាន់ពេលវេលា និងឆាប់រហ័ស។

### អាទិភាពទី៣៖ ការពង្រឹង និងពង្រីកប្រព័ន្ធគាំពារសង្គម

- ការធានាបាននូវវឌ្ឍនភាពប្រកបដោយសមធម៌ ក្នុងការឆ្ពោះទៅសម្រេចចក្ខុវិស័យឆ្នាំ២០៣០ ទាមទារឱ្យមានគោលដៅលើសពីកំណើនសេដ្ឋកិច្ច និងត្រូវផ្តោតលើការបែងចែកឡើងវិញនូវភាគលាភដែលត្រូវកំណត់ដោយរដ្ឋាភិបាល។ គោលដៅនេះអាចធ្វើទៅបាន ដោយការពង្រឹងវឌ្ឍនភាពដ៏រឹងមាំដែលកម្ពុជាបានធ្វើរួចមកហើយ ទៅលើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដោយការពង្រីកបរិមាណ ឱ្យកាន់តែទូលំទូលាយ និងគុណភាពឱ្យកាន់តែល្អប្រសើរ។
- ការប្រមូលចំណូលពន្ធកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្លាស់ប្តូរគោលនយោបាយ និងការកែលម្អការគ្រប់គ្រងច្បាប់ពន្ធដារ នឹងអាចពង្រីកមូលដ្ឋានពន្ធ និងបង្កើនប្រាក់ចំណូលបន្ថែម។ សំណើទាំងនេះ គឺស្របតាមលក្ខណៈនៃវឌ្ឍនភាពផ្នែកស្ថាប័នជាទូទៅ ដែលកម្ពុជាត្រូវមាន ដើម្បីឈានទៅរកស្តង់ដារជីវភាពរស់នៅ មានចំណូលមធ្យមកម្រិតខ្ពស់ និងចំណូលខ្ពស់។
- ការអនុម័តគោលនយោបាយមួយចំនួន របស់រដ្ឋាភិបាលដែលមានគោលដៅដើម្បីគាំពារ និងគាំទ្រគ្រួសារមានចំណូលទាប ទាំងនៅទីជនបទ និងទីក្រុង គឺជាការចាំបាច់ដើម្បីកសាងមូលធនមនុស្ស និងលើកទឹកចិត្តឱ្យមានឆន្ទៈ ក្នុងការធ្វើនវានុវត្តន៍ក្នុងចំណោមកម្មករ និងសហគ្រាសខ្នាតតូច។
- គោលនយោបាយពាក់ព័ន្ធទាំងអស់ គួរតែផ្តល់អាទិភាពដល់ការធានាឱ្យ គ្រួសារមានចំណូលទាបអាចទទួលបាននូវសេវាកម្មចាំបាច់នានា ដូចជាអាហារគ្រប់គ្រាន់ ការថែទាំកុមារ ការអប់រំ លំនៅឋាន ការថែទាំសុខភាព និងសន្តិសុខសង្គម ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការអភិវឌ្ឍមូលធនមនុស្សប្រកបដោយប្រសិទ្ធភាព។

### អាទិភាពទី៤៖ ការវិនិយោគលើធនធានធម្មជាតិរបស់ប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព ដើម្បីធានាបាននូវកំណើន និងការអភិវឌ្ឍរយៈពេលវែង

- និរន្តរភាពបរិស្ថាននិងអព្យាក្រឹតភាពកាបូន ត្រូវតែកើតឡើង ទន្ទឹមគ្នាជាមួយនឹងតម្រូវការកំណើនសេដ្ឋកិច្ច ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាភាគច្រើន ដែលរស់នៅតំបន់ជនបទ ហើយពឹងផ្អែកលើវិស័យកសិកម្ម និងធនធានធម្មជាតិ។
- ការធ្វើបរិវត្តកម្មទៅរកថាមពលស្អាត និងកកើតឡើងវិញសម្រាប់សេដ្ឋកិច្ចបៃតង ត្រូវតែគិតគូរដល់គ្រួសារនៅទីជនបទ និងសហគ្រាសខ្នាតតូច ដែលមានស្ត្រីដើរតួនាទីសំខាន់។
- ការបណ្តុះបណ្តាលជំនាញបៃតង គួរតែត្រូវបានបញ្ជ្រាបនៅក្នុងប្រព័ន្ធអប់រំផ្លូវការ និងក្រៅប្រព័ន្ធ ហើយត្រូវផ្តោតលើអ្នកដែលមានការអប់រំ និងជំនាញមានកម្រិត។
- ការឈានទៅសម្រេច ចក្ខុវិស័យឆ្នាំ២០៣០ ត្រូវតែបញ្ចូលទៅក្នុងការធ្វើទំនើបកម្មសង្គម និងវឌ្ឍនភាពបរិស្ថាន។ ប្រសិនបើតម្រូវការសង្គម និងមហិច្ឆតាបរិស្ថានទាំងនេះ មិនត្រូវបានបំពេញទេនោះ ការឈានទៅសម្រេចចក្ខុវិស័យឆ្នាំ២០៣០ នឹងក្លាយជាសមិទ្ធផលមួយដែលមិនមានភាពពេញលេញ។

### អាទិភាពទី៥៖ ការបន្តពង្រីក កែលម្អ និងធ្វើពិពិធកម្មវិស័យកម្មន្តសាល មានសារៈសំខាន់សម្រាប់ភាពជោគជ័យផ្នែកសេដ្ឋកិច្ចរបស់កម្ពុជា

- វិស័យកម្មន្តសាលនៅតែជាគន្លឹះ ក្នុងការសម្រេចបាននូវកំណើន និងមហិច្ឆតានៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ព្រោះវាបានផ្តល់នូវកំណើនប្រកបដោយនិរន្តរភាព តាមរយៈសកម្មភាពទ្រង់ទ្រាយធំ។ បច្ចុប្បន្ននេះ កម្ពុជាមានឱកាសដ៏សំខាន់ក្នុងការពង្រីក ការធ្វើពិពិធកម្ម និងការកែលម្អវិស័យកម្មន្តសាលរបស់ខ្លួន ដោយទាញយកផលប្រយោជន៍ពីអាជីវកម្ម ដែលកំពុងចាកចេញពីប្រទេសចិន ដោយសារតម្លៃពលកម្មកើនឡើង និងក្រុមហ៊ុនអាជីវកម្មជាច្រើន ដែលកំពុងព្យាយាមធ្វើពិពិធកម្មខ្សែចង្វាក់ផ្គត់ផ្គង់របស់ពួកគេ។ កម្ពុជាគួរតែមានគោលដៅពង្រីកចំណែករបស់ខ្លួន នៅក្នុងវិស័យកម្មន្តសាលសកល ឱ្យបានកាន់តែធំ និងមានលក្ខណៈទំនើបបន្ថែមទៀត។
- ការកែលម្អបរិយាកាស និងបទប្បញ្ញត្តិធុរកិច្ច ការកាត់បន្ថយថ្លៃដើមអាជីវកម្ម តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងភ័ស្តុភារ និងការពង្រឹងសុខភាពជំនាញវិជ្ជាជីវៈ និងការអប់រំកម្លាំងពលកម្មចាប់ពីការអប់រំកុមារតូច រហូតដល់មធ្យមសិក្សា មានសារៈសំខាន់ណាស់ ក្នុងការកែលម្អវិស័យកម្មន្តសាលរបស់កម្ពុជា។
- បញ្ហាប្រឈមថ្មីនៅក្នុង វិស័យកម្មន្តសាលដែលត្រូវដោះស្រាយមាន ដូចជា ការកែលម្អស្តង់ដារបរិស្ថាន និងស្តង់ដារការងារជាដើម។ សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ដែលនៅតែជាទីផ្សារនាំចេញដ៏សំខាន់មួយសម្រាប់កម្ពុជា កំពុងតែបង្កើន

ការសង្កត់ធ្ងន់ថា តើដៃគូពាណិជ្ជកម្មរបស់ខ្លួន បានបំពេញតាមស្តង់ដាបរិស្ថាន និងស្តង់ដាការងារមានកម្រិតខ្ពស់ដែរឬទេ។ ថ្វីដ្បិតកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍនៅឡើយក៏ដោយ ក៏កម្ពុជាត្រូវតែបង្ហាញ និងផ្តល់ភស្តុតាងដែលអាចជឿជាក់បានថា ខ្លួនកំពុងមានវឌ្ឍនភាព ក្នុងការកែលម្អស្តង់ដារបស់ខ្លួនជាបន្តបន្ទាប់។ ការធ្វើដូច្នេះ គឺស្របតាមការប្រាថ្នាចង់បានរបស់សង្គម ដែលស្របជាមួយនឹងចក្ខុវិស័យឆ្នាំ២០៣០ និងចក្ខុវិស័យឆ្នាំ២០៥០ របស់ប្រទេសកម្ពុជា។

### អាទិភាពទី៦៖ ការធ្វើទំនើបកម្ម វិស័យកសិកម្ម ដោយមានការគាំទ្រពីរដ្ឋាភិបាលនៅតែជាកត្តាសំខាន់

- ផលិតកម្មកសិកម្ម បន្តផ្តល់ជាមូលដ្ឋានដ៏សំខាន់សម្រាប់ឧស្សាហកម្មកម្មន្តសាល តាមរយៈការកែច្នៃកសិកម្ម។
- ការសម្រេចបាននូវកំណើនកសិកម្ម នៅតែជាកត្តាសំខាន់ក្នុងការធានាថា កម្រិតប្រាក់ចំណូលទាំងអស់គឺត្រូវបានរួមបញ្ចូល ស្របពេលដែលប្រទេសកម្ពុជាកំពុងឆ្ពោះទៅកាន់គោលដៅចក្ខុវិស័យឆ្នាំ២០៣០។ ប្រជាជនដែលមានចំណូលទាបភាគច្រើន នៅតែប្រកបរបរកសិកម្ម ដូច្នេះ គំនិតផ្តួចផ្តើមនានាដែលផ្តោតគោលដៅលើផលិតកម្មកសិកម្ម នឹងផ្តល់នូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការងារដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។ ទោះបីជាយ៉ាងនេះក្តី វិស័យកសិកម្មប្រឈមមុខនឹងបញ្ហាធំៗជាច្រើននៅឡើយ ជាពិសេសបញ្ហាដែលបណ្តាលមកពីភាពតានតឹងផ្នែកបរិស្ថាន និងការរេចរឹល ព្រមទាំងផលប៉ះពាល់នៃ ការប្រែប្រួលអាកាសធាតុកាន់តែខ្លាំងឡើង។ ដូច្នេះ ការដោះស្រាយបញ្ហាប្រឈមទាំងនេះ និងការធានាឱ្យមានអភិបាលកិច្ចកសិកម្មប្រកបដោយបរិយាបន្ន គឺជាគោលដៅសំខាន់របស់កម្ពុជា។

### អាទិភាពទី៧៖ ការវិនិយោគលើការអប់រំប្រកបដោយគុណភាព ការកសាងជំនាញ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល

- ការអប់រំពីកម្រិតអប់រំកុមារតូច រហូតដល់កម្រិតមធ្យមសិក្សា នៅតែមានសារៈសំខាន់ក្នុងការសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៣០ និងការអភិវឌ្ឍរយៈពេលវែងរបស់ប្រទេស។ ទោះជាយ៉ាងណា អន្តរាគមន៍វិស័យអប់រំ ត្រូវការពេលវេលាច្រើន ដើម្បីសម្រេចចេញជា ផ្លែផ្កានៃការវិនិយោគ។ អន្តរាគមន៍នានាត្រូវតែគិតគូរពី វិសមភាពផ្នែកអប់រំ ដែលស្ត្រីប្រឈមមុខ ក្នុងការទទួលបាននូវវគ្គបណ្តុះបណ្តាល និងការបែងចែកតាមវិស័យ ដើម្បីធានាបាននូវកម្លាំងពលកម្មចម្រុះ និងអាចសម្របខ្លួនបាន។
- ការលើកកម្ពស់គុណភាពនៃ ការអប់រំនៅគ្រប់កម្រិតជាពិសេសការអប់រំពីកម្រិតមត្តេយ្យ រហូតដល់ថ្នាក់ទី១២ គឺចាំបាច់ឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់។ បើគ្មានចំណេះដឹងមូលដ្ឋានរឹងមាំទេ ការបណ្តុះបណ្តាលជំនាញ និងការអប់រំកម្រិតឧត្តមសិក្សា នឹងមិនទទួលបានលទ្ធផលដូចការចង់បាននោះទេ។
- ការអប់រំប្រកបដោយគុណភាព ក៏ផ្តល់នូវការគាំទ្រដ៏សំខាន់ដល់សកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់រដ្ឋាភិបាលផងដែរ ដោយជំរុញភាពធន់របស់សិស្ស គ្រួសារ និងសហគមន៍របស់ពួកគេ ដើម្បីសម្របខ្លួន និងឆ្លើយតបទៅនឹងវិបត្តិ និងការផ្លាស់ប្តូរសេដ្ឋកិច្ចនាពេលអនាគត។ កំណែទម្រង់ប្រព័ន្ធតាមដាននៅកម្រិតវិទ្យាល័យ គួរតែត្រូវបានពិចារណា ដើម្បីលើកទឹកចិត្តសិស្សឱ្យបានកាន់តែច្រើនឱ្យបន្តការសិក្សាលើមុខវិជ្ជា វិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងចាប់អាជីពដែលពាក់ព័ន្ធនឹង STEM ។
- ការលើកកម្ពស់ ឌីជីថលភាវូបនីយកម្ម អាចជំរុញវិស័យផលិតភាពទាំងអស់ ពីវិស័យកម្មន្តសាលទៅវិស័យកសិកម្ម និងវិស័យសេវាកម្ម។ ប្រទេសកម្ពុជាមានវិស័យសេដ្ឋកិច្ចឌីជីថល ដែលកំពុងរីកចម្រើនយ៉ាងស្វាហាប់រួចមកហើយ ប៉ុន្តែនៅតែមានចំណុចដែលត្រូវកែលម្អនូវ អ្វីដែលរដ្ឋាភិបាលអាចធ្វើបាន ដើម្បីបង្កើនហេដ្ឋារចនាសម្ព័ន្ធឌីជីថលជំនាញឌីជីថល និងអក្ខរកម្មឌីជីថល និងបិទគម្លាតឌីជីថល រវាងគ្រួសារដែលមានចំណូលទាប និងចំណូលខ្ពស់។ ការធ្វើឱ្យប្រសើរឡើងនូវឌីជីថលភាវូបនីយកម្មរបស់កម្ពុជា នឹងមិនត្រឹមតែធានាបាននូវ ដំណើរការប្រកបដោយបរិយាបន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ច ជាអតិបរមាដល់ប្រទេសជាតិផងដែរ។

## ការអភិវឌ្ឍក្នុងដំណាក់កាលបន្ទាប់របស់កម្ពុជាកំពុងស្ថិតនៅចំណុចរបត់ដ៏សំខាន់

កម្ពុជានឹងត្រូវពឹងផ្អែកលើភាពខ្លាំងរបស់ខ្លួន ដើម្បីសម្រេចបាននូវមហិច្ឆតាចក្ខុវិស័យឆ្នាំ២០៣០របស់ខ្លួន។ ភាពខ្លាំងទាំងនេះរួមមាន អ្នកដឹកនាំជំនាន់ថ្មីដែលមានសមត្ថភាពពេញលេញ កម្លាំងពលកម្មវ័យក្មេងដែលចេះបន្សាំខ្លួននគរូបនីយកម្មយ៉ាងឆាប់រហ័ស ការចាប់យកឱកាសពីខាងក្រៅ ការបន្តធ្វើសមាហរណកម្មក្នុងតំបន់ និងពិភពលោក កំណើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចក្នុងតំបន់ និងសេដ្ឋកិច្ចកំពុងលូតលាស់ថ្មី និងការចាប់យកបច្ចេកវិទ្យាថ្មីៗ។ ទន្ទឹមនឹងនេះ កម្ពុជានឹងត្រូវដោះស្រាយបញ្ហាប្រឈម និងហានិភ័យសំខាន់ៗមួយចំនួន ដូចជា ការប្រែប្រួលសេដ្ឋកិច្ចសកលដែលមិនអាចទស្សន៍ទាយបាន ការកើនឡើងវិសមភាព ការកើនឡើងនៃការបំផ្លាញបរិស្ថាន និងការប្រែប្រួលអាកាសធាតុ និងការបណ្តុះបណ្តាលមនុស្សជំនាន់ថ្មីសម្រាប់កម្លាំងពលកម្មទំនើប។ កម្ពុជាត្រូវតែបន្តរបៀបវារៈនៃការធ្វើកំណែទម្រង់រចនាសម្ព័ន្ធ និងស្ថាប័ន ដូចដែលមានចែងនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ និងត្រូវសហការឱ្យបានជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ រួមទាំងវិទ្យាស្ថានស្រាវជ្រាវឯករាជ្យ ដូចជា CDRI ជាដើម ដើម្បីវិភាគ និងកំណត់អាទិភាពគោលនយោបាយពាក់ព័ន្ធ។

"ការសម្រេចបាននូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន គឺជាដំណើរវែងឆ្ងាយដែលទាមទារឱ្យមានការចូលរួមជិតស្និទ្ធ ពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ការប្តេជ្ញាចិត្តខ្ពស់ កិច្ចសហការស្អិតល្មួត និងការតម្កល់ផលប្រយោជន៍ជាតិជាធំ។"

*សុន្ទរកថារបស់ អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី*
*រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្លែងក្នុងពិធីបិទសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី១៥*

## សង្ខេបអនុសាសន៍គោលនយោបាយ និងសារគន្លឹះ៖

មុនការរាតត្បាតនៃជំងឺកូវីដ-១៩ កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់កម្ពុជា បានផ្តល់មូលដ្ឋានគ្រឹះ សម្រាប់ការឈានទៅសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប (LMIC) ខណៈដែលការធ្វើពិពិធកម្មសេដ្ឋកិច្ច និងអ្នកដែលមានលទ្ធភាពទទួលបានកំណើននោះ ប្រកបដោយបរិយាបន្ននៅមានកម្រិតនៅឡើយ។ ទោះបីជាយ៉ាងនេះក្តី កំណើនសេដ្ឋកិច្ចនាពេលអនាគតរបស់ប្រទេសកម្ពុជា ត្រូវតែកើតចេញពីប្រភពដែលរឹងមាំ និងចម្រុះ ហើយកំណើននេះដែរត្រូវបែងចែកប្រកបដោយសមធម៌ក្នុងចំណោមប្រជាពលរដ្ឋ។

បន្ថែមលើគោលដៅនៃចក្ខុវិស័យឆ្នាំ២០៣០ អ្នកចូលរួមក្នុងសន្និសីទចក្ខុវិស័យបានឯកភាពរួមគ្នាថា គោលដៅចំនួនពីរ ខាងក្រោមនេះ ត្រូវតែសម្រេចឱ្យបានក្នុងពេលដំណាលគ្នា៖

- កម្ពុជាត្រូវតែធានាថា កំណើនសេដ្ឋកិច្ចនាពេលអនាគត គឺប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន ដោយមានគោលបំណងរួមបញ្ចូលទាំងស្ត្រី និងការប្រយុទ្ធប្រឆាំងនឹងការរើសអើងយេនឌ័រ ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមដែលកើតឡើងដោយសារតែការប្រែប្រួលអាកាសធាតុ។
- កម្ពុជាត្រូវតែកសាងមូលដ្ឋានគ្រឹះនៅពេលនេះ ដើម្បីវឌ្ឍនភាពនាពេលអនាគត ក្នុងការឆ្ពោះទៅរកការប្រែក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយជៀសវាងនូវអ្វីដែលគេហៅថា អន្ទាក់នៃប្រទេសមានចំណូលមធ្យម។

## **អាទិភាពកំណែទម្រង់គន្លឹះ ៧ ចំណុច៖**

- **អាទិភាពទី១៖** ការដោះស្រាយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច ដែលបណ្ដាលមកពីជំងឺរាតត្បាតកូវីដ-១៩ ដោយអនុវត្តអាទិភាពរយៈពេលខ្លី ដូចជាការបង្កើតថ្នាក់សិក្សាបំប៉នបន្ថែម ការផ្ដល់កម្មវិធីគាំពារសង្គមឱ្យបានកាន់តែច្រើន និងការទទួលបានការវិនិយោគផ្ទាល់ពីបរទេស (FDI) បន្ថែមទៀតក្នុងវិស័យកម្មន្តសាល។
- **អាទិភាពទី២៖** ការលើកកម្ពស់ស្ថាប័នប្រកបដោយគណនេយ្យភាព និងបរិយាបន្ន ដើម្បីផ្ដល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងមានគុណភាពខ្ពស់ តាមរយៈការធ្វើស្តង់ដានៃការប្រមូលទិន្នន័យ និងការកែលម្អការគ្រប់គ្រងទិន្នន័យ។
- **អាទិភាពទី៣៖** ការពង្រឹង និងពង្រីកប្រព័ន្ធគាំពារសង្គម ដោយការកែលម្អច្បាប់ពន្ធដារ ដើម្បីបង្កើនប្រាក់ចំណូលរបស់រដ្ឋាភិបាល និងការធានាឱ្យគ្រួសារដែលមានចំណូលទាប អាចទទួលបាននូវសេវាកម្មមូលដ្ឋាន។
- **អាទិភាពទី៤៖** ការវិនិយោគលើ វិស័យធនធានធម្មជាតិរបស់កម្ពុជាប្រកបដោយនិរន្តរភាព ដើម្បីធានាបាននូវកំណើន និងការអភិវឌ្ឍរយៈពេលវែងតាមរយៈការពង្រីកថាមពលស្អាត និងកកើតឡើងវិញ និងការអភិរក្សបរិស្ថាន ដើម្បីគាំទ្រដល់ប្រជាជនកម្ពុជាមួយចំនួនធំ ដែលពឹងផ្អែកខ្លាំងលើវិស័យកសិកម្ម។
- **អាទិភាពទី៥៖** ការបន្តពង្រីក កែលម្អ និងធ្វើពិពិធកម្មវិស័យកម្មន្តសាល ដោយចាប់យកឱកាសនានាក្នុងវិស័យកម្មន្តសាល ដែលកំពុងចាកចេញពីប្រទេសចិន និងពង្រឹងបទប្បញ្ញត្តិអាជីវកម្មរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹង តម្រូវការជាអន្តរជាតិ ក្នុងការធ្វើឱ្យប្រសើរឡើងថែមទៀតនូវការការពារសិទ្ធិការងារ និងបរិស្ថាន។
- **អាទិភាពទី៦៖** ការធ្វើទំនើបកម្មវិស័យកសិកម្មដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ដោយផ្ដល់ការគាំទ្រពីរាជរដ្ឋាភិបាលចំពោះការកែច្នៃកសិកម្ម និងការកាត់បន្ថយការរេចរឹល និងភាពតានតឹងផ្នែកកសិកម្ម។
- **អាទិភាពទី៧៖** ការវិនិយោគលើការអប់រំប្រកបដោយគុណភាព ការកសាងជំនាញ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដោយធ្វើកំណែទម្រង់ប្រព័ន្ធតាមដានថ្នាក់មធ្យមសិក្សា ការប្រយុទ្ធប្រឆាំងនឹងភាពលម្អៀងចំពោះស្ត្រីដែលចូលរួមក្នុងវិស័យមួយចំនួន ដូចជា STEM និងការបង្កើតថ្នាលឌីជីថលដែលបង្កើនទំនាក់ទំនងរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ។

សម្រាប់ព័ត៌មានលម្អិតផ្សេងៗទៀត
សូមចូលទៅកាន់គេហទំព័រសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣
**https://coc2023.cdri.org.kh**


**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

អាសយដ្ឋាន៖ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣
អ៊ីម៉ែល៖ cdri@cdri.org.kh   គេហទំព័រ៖ www.cdri.org.kh



រៀបចំដោយ

ក្នុងភាពជាដៃគូជាមួយ